# លោកទូតស្វីសអះអាងពីប្រជាជននិងរដ្ឋាភិបាលស្វីសនឹងបន្តគាំទ្រមន្ទីរពេទ្យកុមាររបស់លោកសាស្ត្រាចារ្យBeat Richner

**ភ្នំពេញ៖** លោកឯកអគ្គរដ្ឋទូតស្វីសប្រចាំតំបន់បានអះអាងថា រដ្ឋាភិបាលនិងប្រជាជនស្វីសទាំងមូលនឹងបន្តគាំទ្រដល់សកម្មភាពរបស់លោកសាស្ត្រាចារ្យ Beat Richner ដែលបានបើកមន្ទីរពេទ្យដ៏ធំប្រចាំកម្ពុជាហើយធ្វើការព្យាបាលកុមារកម្ពុជាដោយឥត គិតថ្លៃ ។



លោក Christoph Burgener ឯកអគ្គរដ្ឋទូតស្វីស ប្រចាំតំបន់ និងនិស្សិតស្វីស-កម្ពុជា ចូលរួមក្នុងវគ្គបណ្តុះបណ្តាល(រូប:លាងញូរ)

លោកគ្រីស្តុប ប៊ឺហ្គើនឺ Christoph Burgener ឯកអគ្គរដ្ឋទូតស្វីសប្រចាំកម្ពុជា ឡាវ និងប្រទេសភូមាបានថ្លែងក្នុងនិងក្រោយពិធីបើកវគ្គបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សាផ្នែកវេជ្ជសាស្ត្រដល់និស្សិតខ្មែរ និងស្វីស កាលពីដើមសប្តាហ៍នេះថា រដ្ឋាភិបាលស្វីសបានជួយមន្ទីរពេទ្យនេះចំនួន៣-៤លានដុល្លារក្នុងមួយឆ្នាំ នៅពេលមន្ទីរពេទ្យនេះបានធ្វើការពិនិត្យ និងព្យាបាលកុមារ កម្ពុជាជាង១០លាននាក់ចាប់តាំងពីបើករហូតមកដល់ពេលនេះ ។ ឪពុកម្តាយ បងប្រុស បងស្រី បានបញ្ជូនកូននិងប្អូនរបស់ពួកគេជាង១លាននាក់ជារៀងរាល់ឆ្នាំមករកលោកវេជ្ជបណ្ឌិត Beat Richner ។

លោកបន្តថា “ប្រជាជនស្វីសទាំងអស់ មានមោទនភាពចំពោះគាត់ ដែលគាត់មិនត្រឹមតែមានទស្សនៈវិស័យប៉ុណ្ណោះទេ ប៉ុន្តែគាត់បានធ្វើការអនុវត្តន៍ សកម្មភាពរបស់គាត់ក្នុងការពិនិត្យនិងព្យាបាលកុមារកម្ពុជាដោយពិតប្រាកដ”។ លោកបន្តថា “ខ្ញុំគិតថាប្រជាជនស្វីសកាន់តែច្រើនមានការប្តេជ្ញាចិត្តខ្ពស់បំផុត ក្នុងការគាំទ្រគាត់ហើយលោក Beat Richner គឺជាវីរៈបុរសម្នាក់នៅប្រទេសស្វីសប្រជាជនស្វីសគ្រប់គ្នាស្គាល់គាត់។ ពួកគេនឹងនៅជាមួយគាត់ និងបន្តគាំទ្រគាត់ខ្ញុំពិតជាមានការជឿជាក់បែបនេះ”។

លោក Christoph Burgener បានបន្តដោយរំលឹកថា “កាលពី២ឆ្នាំមុនខ្ញុំបានមកដល់ប្រទេសកម្ពុជា ហើយបានជិះតាក់ស៊ីពីព្រលានយន្តហោះចូលមកក្រុងសៀមរាប ពេលនោះអ្នកបើកតាក់ស៊ីបានសួរខ្ញុំថាអ្នកមកពីណា? ខ្ញុំប្រាប់ថា មកពីប្រទេសស្វីស។ អ្នករត់តាក់ស៊ីបានប្រាប់ខ្ញុំថា មានវេជ្ជបណ្ឌិតមកពីស្វីសម្នាក់ គាត់គឺជាព្រះនៅទីនេះ”។

លោកវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានមានប្រសាសន៍ថា យើងបានបន្តធ្វើការក្នុងភាពជាដៃគូជាមួយគ្នា ដើម្បីលើកកម្ពស់សុខភាពសាធារណៈ ពិសេសគោលនយោបាយផ្តល់ការពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃនៅមន្ទីរពេទ្យនេះ ដែលមានសេវាព្យាបាលប្រកបដោយគុណភាព និងមានសម្ភារៈឧបករណ៍មានភាពទំនើបៗ និងទាន់សម័យក្នុងសកលលោក ។ លោកបន្តថា សកម្មភាពបែបនេះ គឺពិតជាឆ្លើយតបនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា តាមការចង្អុលបង្ហាញ និងការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាប្រមុខ ។

លោកបន្តថា “ថ្ងៃនេះយើងពិតជាមានមោទនភាព និងក្តីរីករាយដែលមានវគ្គបណ្តុះបណ្តាលបែបនេះ។ នេះជាឱកាសល្អក្នុងការបង្កើនសមត្ថភាពរបស់និស្សិតផ្នែកវេជ្ជសាស្ត្រ ហើយយើងប្តេជ្ញាចិត្តក្នុងការគាំទ្រ និងបន្តធ្វើការជាមួយលោកសាស្ត្រាចារ្យ Beat-Richner”។ លោកបន្តថា “យើងក៏មានមោទនភាពក្នុងការចងសម្ព័ន្ធភាពជាមួយប្រជាជនស្វីស ដែលបាននិងកំពុងបន្តការគាំទ្រដល់ប្រជាជនកម្ពុជា”។

លោកសាស្ត្រាចារ្យBeat-Richner បានមានប្រសាសន៍ថា “ខ្ញុំបានទទួលប្រាក់មួយចំនួនធំដើម្បីធ្វើការបណ្តុះបណ្តាល និស្សិតកម្ពុជានិងនិស្សិតស្វីសនៅពេលនេះ ប៉ុន្តែខ្ញុំខកចិត្តដែលវេជ្ជបណ្ឌិតនៅប្រទេសស្វីសនិងជុំវិញពិភពលោកមើលឃើញតែបញ្ហាលុយក្នុងការពិនិត្យនិងព្យាបាលអ្នកជំងឺ”។ លោកបន្តថា “មានវេជ្ជបណ្ឌិត សាស្ត្រាចារ្យមួយចំនួននៅប្រទេសស្វីស និងប្រទេសជាច្រើនទៀតមានបញ្ហាខួរក្បាលយ៉ាងធ្ងន់ធ្ងរ”។

លោកសាស្ត្រាចារ្យបានបន្តដោយបង្ហាញទៅកាន់ក្រុមនិស្សិតទាំងខ្មែរ និងស្វីសថា នៅមន្ទីរពេទ្យគន្ធបុប្ផាក្រុងភ្នំពេញ មានកុមារជាង៣.០០០នាក់ ក្នុងមួយថ្ងៃៗមករកសេវាពិនិត្យនិងព្យាបាល ហើយយើងមានប៉ូលិសចំនួន២៥នាក់ជួយការពារខ្លាចមានបញ្ហាគ្រោះថ្នាក់ជាន់គ្នារបស់អ្នកមករកសេវាព្យាបាល។ លោកបន្តថា ប្រសិនជាយើងព្យាបាលដោយយកប្រាក់ អ្នកក្រីក្រនឹងមិនបញ្ជូនកូនរបស់ពួកគេមករកការពិនិត្យព្យាបាលជំងឺរបេង ដែលរយៈពេលព្យាបាលមានចាប់ពី៩ ដល់១២ខែ ប៉ុន្តែនៅទីនេះយើងមិនត្រឹមធ្វើការព្យាបាលជូនពួកគាត់ដោយមិនគិតប្រាក់នោះទេ តែយើងបានផ្តល់ប្រាក់សម្រាប់ថ្លៃធ្វើដំណើរជូនពួកគាត់ ដើម្បីឱ្យពួកគាត់នាំកូនកើតជំងឺរបេងមកធ្វើការព្យាបាលរហូតដល់ជាសះស្បើយ ។

លោក Beat Richner បានចំអកឱ្យគ្រូពេទ្យមួយចំនួនថា “ប្រសិនជាអ្នកធ្វើវេជ្ជបណ្ឌិត ហើយធ្វើការព្យាបាលដោយគិតតែប្រាក់ មិនឱ្យតម្លៃជីវិតមនុស្ស សូមស្វែងរកការងារផ្សេងៗធ្វើទៅ”។ លោកបន្ថែមថា “នៅគ្រប់វប្បធម៌ប្រទេសនីមួយៗមានភាពផ្សេងៗគ្នា ឬយ៉ាងណាមិនសំខាន់នោះទេ ប៉ុន្តែអ្វីដែលសំខាន់គឺការពិនិត្យព្យាបាល ដើម្បីសង្គ្រោះជីវិតអ្នកជំងឺ”៕

**ដោយ ចំណាន**